# សេចក្តីជូនដំណឹង
# សិក្ខាសាលាផ្សព្វផ្សាយស្តីពី
# "នីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោង ភាពជាដៃគូរវាងរដ្ឋ និងឯកជន"

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយមូលនិធិអភិវឌ្ឍន៍មូលធននៃអង្គការសហប្រជាជាតិ (United Nation Capital Development Fund-UNCDF) នឹងរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី **«នីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន»** ឬហៅជាភាសាអង់គ្លេសថា «The Standard Operating Procedures for Public-Private Partnerships Projects» ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង ០៨:៣០ ព្រឹក នៅសណ្ឋាគារ សូហ្វិតែល ភ្នំពេញភូគីត្រា ដើម្បីផ្សព្វផ្សាយ ឱ្យកាន់តែទូលំទូលាយដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍, ស្ថាប័នហិរញ្ញវត្ថុ, ក្រុមហ៊ុនទីប្រឹក្សាក្នុងវិស័យវិនិយោគសាធារណៈ, ក្រុមហ៊ុនមេធាវី, ក្រុមហ៊ុនធានារ៉ាប់រង, ក្រុមហ៊ុនជាតិ និងអន្តរជាតិ ពាក់ព័ន្ធ និងវិស័យឯកជនផ្សេងទៀត។

សិក្ខាសាលាផ្សព្វផ្សាយនេះ នឹងប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិត **ផាន់ ផល្លា** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមនេះ គឺក្នុងគោលបំណងគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន(ភរឯ) ដែលបានចូលជាធរមាន នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ព្រមទាំងការរៀបចំការអនុវត្ត និងការគ្រប់គ្រងគម្រោង ភ.រ.ឯ. ឱ្យបានពេញលេញ និងមានប្រសិទ្ធភាពនៅកម្ពុជា។

គួរបញ្ជាក់ថា **«នីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន»** នេះត្រូវបានដាក់ឱ្យប្រើដោយអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាលកម្ពុជា។

អាស្រ័យហេតុនេះ សូមសាធារណជន និងអ្នកសារព័ត៌មានទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងចូលរួម សិក្ខាសាលាស្តីពី **«នីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន»** ដែលនឹងប្រព្រឹត្តទៅដូចរៀបរាប់ខាងលើកុំបីអាក់ខាន៕

សូមស្កេន QR Code ខាងក្រោមនេះ ដើម្បីទាញយកឯកសារពាក់ព័ន្ធ
សម្រាប់កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ÷